# What do I need to know if my child gets a formal caution?

Parent/carer information

# តើខ្ញុំចាំបាច់ត្រូវដឹងពីអ្វីខ្លះ ប្រសិនបើកូនរបស់ខ្ញុំទទួលបានការព្រមានជាផ្លូវការមួយ?

## ព័ត៌មានសម្រាប់ឪពុកម្ដាយ/អ្នកថែទាំ

### តើអ្វីជាការព្រមានជាផ្លូវការចំពោះអាកប្បកិរិយាគួរឱ្យព្រួយបារម្ភ?

អាកប្បកិរិយាគួរឱ្យព្រួយបារម្ភ គឺជាទង្វើអ្វីមួយដែលនរណាម្នាក់ធ្វើដែលអាចបង្ក ឬបានបង្កឱ្យមានការឈឺចាប់ ឬគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃទៀត។ ការព្រមានជាផ្លូវការប្រាប់សិស្សម្នាក់ថា អាកប្បកិរិយារបស់ពួកគេបានបង្ក ឬអាចបង្កការឈឺចាប់ ឬគ្រោះថ្នាក់ដល់ខ្លួនឯង និងមនុស្សដទៃទៀត ឬបង្កហានិភ័យដែលមិនអាចទទួលយកបានដល់ការបង្រៀន និងការរៀនសូត្រ។ ការព្រមាននេះត្រូវបានតាក់តែងឡើងដើម្បីឱ្យអ្នក និងកូនរបស់អ្នកដឹងថាអាកប្បកិរិយារបស់ពួកគេចាំបាច់ត្រូវតែកែលម្អ។

ការព្រមានជាផ្លូវការគឺជាលិខិតមួយ ដែលអាកប្បកិរិយាគួរឱ្យព្រួយបារម្ភរបស់កូនអ្នកត្រូវបានកត់ត្រាទុក។ កូនរបស់អ្នកនឹងមិនត្រូវបានបញ្ឈប់បណ្ដោះអាសន្ននៅពេលនេះទេ។

### តើមានអ្វីកើតឡើងប្រសិនបើកូនរបស់ខ្ញុំទទួលបានការព្រមានជាផ្លូវការ?

សាលារៀននឹងពិភាក្សាអំពីអាកប្បកិរិយាគួរឱ្យព្រួយបារម្ភនោះ ហើយពន្យល់ពីការព្រមានជាផ្លូវការដល់កូនរបស់អ្នក។ នាយកសាលានឹងផ្ដល់ឱ្យអ្នកនូវការព្រមានជាផ្លូវការជាលាយលក្ខណ៍អក្សរមួយច្បាប់ផងដែរ។

គោលបំណងនៃការព្រមានជាផ្លូវការ គឺផ្ដល់ឱ្យកូនរបស់អ្នកនូវពេលវេលាដើម្បីយល់ដឹងពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ពួកគេ និងយល់ព្រមលើផែនការគាំទ្រមួយ ដើម្បីចូលរួមក្នុងយុទ្ធសាស្ត្រគាំទ្រអាកប្បកិរិយាវិជ្ជមាននានា។ សាលារៀននឹងផ្ដល់ឱ្យអ្នក និងកូនរបស់អ្នកនូវឱកាសដើម្បីជួបជាមួយពួកគេដើម្បីពិភាក្សាអំពីអាកប្បកិរិយា និងរៀបចំផែនការ ឬពិនិត្យឡើងវិញនូវការគាំទ្រដែលកូនរបស់អ្នកត្រូវការ។

អ្នកអាចនាំអ្នកគាំទ្រម្នាក់មកជាមួយអ្នក ដើម្បីចូលរួមកិច្ចប្រជុំណាមួយជាមួយសាលារៀន។

ការព្រមានជាផ្លូវការចំពោះអាកប្បកិរិយាគួរឱ្យព្រួយបារម្ភ ត្រូវបានដាក់ធ្វើឱ្យដំណើរការរហូតដល់ទៅ50ថ្ងៃសិក្សា។ ក្នុងអំឡុងពេលនេះ កូនរបស់អ្នកអាចនឹងត្រូវបានបញ្ឈប់បណ្ដោះអាសន្ន ប្រសិនបើអាកប្បកិរិយានោះកើតឡើងម្ដងទៀត ឬចំពោះអាកប្បកិរិយាគួរឱ្យព្រួយបារម្ភផ្សេងទៀត។

### តើខ្ញុំធ្វើដូចម្ដេចប្រសិនបើកូនរបស់ខ្ញុំទទួលបានការព្រមានជាផ្លូវការ?

ស្ទើរតែគ្រប់កុមារ ពេលខ្លះនឹងធ្វើអ្វីៗដែលមិនគោរពតាមវិន័យសាលា ឬក្រមអាកប្បកិរិយាសម្រាប់សិស្ស។ ពេលខ្លះ នៅពេលដែលរឿងនេះកើតឡើង ការព្រមានជាផ្លូវការមួយនឹងត្រូវបានផ្ដល់ឱ្យ។ ព័ត៌មានបន្ថែមគឺអាចរកបានស្ដីពីអ្វីដែលត្រូវធ្វើប្រសិនបើកូនរបស់អ្នកមានបញ្ហានៅសាលារៀន។

ប្រសិនបើកូនរបស់អ្នកទទួលបានការព្រមានជាផ្លូវការ នេះមានន័យថាមានអាកប្បកិរិយាមួយដែលត្រូវការការយកចិត្តទុកដាក់។ ការចូលរួមរបស់អ្នកជាមួយសាលារៀនមានសារៈសំខាន់ណាស់ ក្នុងការគ្រប់គ្រងអាកប្បកិរិយារបស់កូនអ្នក និងការបង្កើតដំណោះស្រាយរួមគ្នា។ សូមពិភាក្សាជាមួយនាយកសាលាអំពីការព្រមានជាផ្លូវការនេះ និងធ្វើការជាមួយក្រុមដែលគាំទ្រកូនរបស់អ្នកដើម្បីស្វែងរកដំណោះស្រាយមួយចំនួន។

### ចុះប្រសិនបើអាកប្បកិរិយានោះកើតឡើងម្ដងទៀត?

ប្រសិនបើអាកប្បកិរិយាគួរឱ្យព្រួយបារម្ភនោះកើតឡើងម្ដងទៀត នាយកសាលាអាចសម្រេចចិត្តបញ្ឈប់បណ្ដោះអាសន្នកូនរបស់អ្នក។ ការសម្រេចចិត្តបញ្ឈប់បណ្ដោះអាសន្នកូនរបស់អ្នកនឹងកើតឡើងប៉ុណ្ណោះ បន្ទាប់ពីនាយកសាលាពិនិត្យមើលអាកប្បកិរិយានោះ និងតម្រូវការបុគ្គលរបស់កូនអ្នក ហើយនិងកុមារដទៃទៀតទៀត។ ព័ត៌មានស្ដីពីការបញ្ឈប់បណ្ដោះអាសន្នសិស្សគឺអាចរកបាន។

### តើខ្ញុំត្រូវធ្វើដូចម្ដេចប្រសិនបើខ្ញុំនៅតែមានការព្រួយបារម្ភ?

ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការរៀនសូត្រ អាកប្បកិរិយា ឬសុខុមាលភាពរបស់កូនអ្នកនៅសាលារៀន កន្លែងដ៏ល្អបំផុតដើម្បីចាប់ផ្ដើមគឺនិយាយជាមួយគ្រូជំនួយការនាយកសាលា ឬនាយករង។ បញ្ហាភាគច្រើនអាចដោះស្រាយបាន ដោយការនិយាយទៅកាន់មនុស្សដែលស្គាល់កូនរបស់អ្នក និងអំពីស្ថានភាពនោះ។

ពេលខ្លះ អ្នកប្រហែលជាត្រូវនិយាយជាមួយនរណាម្នាក់ផ្សេងទៀត។ សាលារៀនរបស់អ្នក អាចផ្ដល់ឱ្យអ្នកនូវព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យអប់រំក្នុងតំបន់របស់អ្នក ដែលប្រហែលជាអាចជួយបាន។ សូមគិតផងដែរអំពីការនិយាយទៅកាន់វេជ្ជបណ្ឌិតរបស់កូនអ្នក ប្រសិនបើអ្នកគិតថាអាចមានហេតុផលវេជ្ជសាស្ត្រចំពោះការព្រួយបារម្ភរបស់អ្នក។

ព័ត៌មានបន្ថែមស្ដីពីការតស៊ូមតិសម្រាប់កូនរបស់អ្នកគឺអាចរកបាន ក៏ដូចជាធម្មនុញ្ញសហគមន៍សាលារៀនរបស់យើង ដែលគូសបញ្ជាក់អំពីវិធីនានាដើម្បីប្រាស្រ័យទាក់ទងជាមួយសាលារៀន។

### តើខ្ញុំអាចទទួលបានព័ត៌មានអ្វីខ្លះពីសាលារៀន?

អ្នកអាចសួររកព័ត៌មានបន្ថែមពីសាលារៀន អំពីអ្វីដែលបានកើតឡើង និងមូលហេតុ។ សាលារៀនគួរតែពន្យល់ដល់អ្នកអំពីហេតុផលនៅពីក្រោយការសម្រេចចិត្តណាមួយ សកម្មភាពនឹងកើតឡើង និងអ្វីដែលត្រូវធ្វើប្រសិនបើអ្នកមានបញ្ហា។

### សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកមានបំណងចង់ទាក់ទងមកសាលារៀន ហើយត្រូវការជំនួយផ្នែកភាសាអង់គ្លេស សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទតាមលេខ 131 450 ប្រាប់ពួកគេពីភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យការីទូរសព្ទទូរសព្ទទៅសាលារៀន។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទដើម្បីជួយអ្នកនៅក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។